អន្តរហ្វ៊ីរ
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ វត្ត និង ព្រះសង្ឃ ។

www.hoksavann.org

ថ្ងៃទី១១ ឧសភា ២០១៣



ពាក្យថា ***វត្ត*** ជាភាសាខ្មែរ ដែលចេញមកពីភាសាបាលីថា ***វត្តំ*** ប្រែថា ទីកន្លែងសំរាប់គោរពបូជា ជាកន្លែងសំរាប់ព្រះសង្ឃគង់នៅ ។ សេចក្តីថា ព្រះសង្ឃពុំអាចរស់នៅជាមួយគ្រហស្ថបានទេ គឺត្រូវរស់នៅកន្លែងមួយដាច់ដោយឡែក ដែលហៅថាវត្តនេះឯង ។ ក្នុងភាសាបាលី មានប្រើពាក្យមួយទៀតថា ***អារាម*** ប្រែថា ជាទីរីករាយចិត្ត គឺបើគេមានទុក្ខកង្វល់ផ្លូវចិត្ត ពេលណាគេចូលវត្ត បានទាញអារម្មណ៍គេឲ្យរីករាយផ្លូវចិត្តក្នុងភាពស្ងប់ ព្រោះវត្តជាទីរម្ងាប់នូវអំពើបាបនិងកង្វល់ផ្លូវចិត្ត ។ ក្រៅពីព្រះសង្ឃ វត្តនៅមានវត្ថុជាទីគោរពសក្ការៈដូចជាព្រះវិហារព្រះពុទ្ធរូបគម្ពីរព្រះត្រៃបិដកជាដើម។គេសង្កេតឃើញនៅប្រទេសកម្ពុជា បើមានភូមិនៅកន្លែងណា តែងតែមានវត្តព្រះពុទ្ធសាសនានៅកន្លែងនោះ និងនៅតាមទីក្រុងក៏មានដូចគ្នាដែរ ។ ពុទ្ធសាសនិកជនខ្មែរទុកវត្តអារាមជាទីគោរពបូជារួមគ្នា ក្នុងការបំពេញបុណ្យទាននិងការរម្ងាប់អំពើបាប ។

ពាក្យថា ***ព្រះសង្ឃ*** ប្រែថា ក្រុមឬពួកដែលចេញមកពីភាសាបាលីថា ***សង្ឃោ*** ។បានដល់ក្រុមឬពួករបស់បព្វជិតឬអ្នកបួស គឺភិក្ខុនិងសាមណេរ ដែលជាអ្នកលះបង់ពីភេទជាគ្រហស្ថ មកបួសជា ***ឧត្តមភេទ*** កាន់ព្រះពុទ្ធសាសនាមានកម្រិតខ្ពស់ ព្រោះឃើញភ័យក្នុងវដ្តសង្សារ ពីការកើតចាស់ឈឺស្លាប់ ហើយរស់នៅក្រោមធម្មវិន័យរបស់ព្រះពុទ្ធ ។ ព្រះសង្ឃព្រះពុទ្ធសាសនាមានភារកិច្ចពីរយ៉ាង គឺសិក្សាធម្មវិន័យរបស់ព្រះពុទ្ធឲ្យយល់ច្បាស់ និងប្រតិបត្តិតាមឲ្យបានត្រឹមត្រូវ ។ ក្រៅពីនោះ ព្រះសង្ឃមានតួនាទីមួយទៀត គឺការយកធម្មវិន័យរបស់ព្រះពុទ្ធ មកពន្យល់ណែនាំពុទ្ធបរិស័ទឲ្យបានយល់ច្បាស់ និងប្រតិបត្តិតាមឲ្យបានត្រឹមត្រូវ ។ ដូច្នេះព្រះសង្ឃជាភេទពិសេស ជាភេទបរិសុទ្ធ អាចមានឱកាសប្រតិបត្តិធម៌ សីល សមាធិ បញ្ញា និងផ្សព្វផ្សាយ ព្រមទាំងរក្សាការពារព្រះពុទ្ធសាសនាបានច្រើនជាងគ្រហស្ថ ។ ព្រះសង្ឃស្ថិតនៅក្នុងបា-វចនាទាំងបីនៃព្រះត្រៃសរណគមន៍គឺ ***ព្រះពុទ្ធ ព្រះធម៌*** និង ***ព្រះសង្ឃ*** ដែលពុទ្ធបរិស័ទខ្មែរយកជាទីពឹងទីរលឹកស្មើដោយជីវិតរបស់ខ្លួន ដូចបាលីសូត្រនមស្ការថា ***នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ ធម្មោ សង្ឃោ មេ សរណំ វរំ*** ប្រែថា វត្ថុដទៃជាទីពឹង ទីរលឹកនៃខ្ញុំព្រះករុណាពុំមានឡើយ មានតែ***ព្រះពុទ្ធ ព្រះធម៌*** និង ***ព្រះសង្ឃ*** ជាទីពឹង ទីរលឹកស្មើដោយជីវិតរបស់ខ្ញុំព្រះករុណា ។ ដូច្នេះ ***ព្រះសង្ឃជាទីគោរព*** ការប្រើពាក្យហៅព្រះសង្ឃ ក៏ឲ្យបានសមរម្យដែរ គឺត្រូវប្រើពាក្យ ***«ព្រះសង្ឃ»*** កុំប្រើពាក្យថា ***«លោកសង្ឃ»*** ដូច្នេះឡើយ ព្រោះពាក្យថា ***«លោក»*** គេមានប្រើសំរាប់ហៅគួរសមជាមួយគ្រហស្ថ ដូចហៅឈ្មោះលោកនេះលោកនោះជាដើម ។ ការហៅដោយមិនប្រើពាក្យ ***«ព្រះ»*** នៅខាងដើម ជាពាក្យហៅខ្វះការគោរពចំ-ពោះព្រះសង្ឃ ។ ***ព្រះសង្ឃជាឧត្តមភេទ*** មានគុណធម៌ មានសីលគុណជាដើម គួរគោរពជាអ្នកលះបង់អំពើអាក្រក់អស់ហើយ បានដល់ ***អរិយសង្ឃ*** និងព្រះសង្ឃកំពុងព្យាយាមលះបង់បានដល់ ***សម្មតិសង្ឃ*** ។

វត្តអារាមនៃព្រះពុទ្ធសាសនាខ្មែរ ពុំមែនត្រឹមតែជាមជ្ឈមណ្ឌលសំរាប់គោរពប្រតិបត្តិព្រះពុទ្ធសាសនាប៉ុណ្ណោះទេ លើសពីនេះទៀតជាមជ្ឈមណ្ឌលសំរាប់រក្សានិងផ្សព្វផ្សាយនូវវប្បធម៌អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ ប្រពៃណីទំនៀមទំលាប់គ្រប់ផ្នែករបស់ខ្មែរថែមទៀត ។ ពុទ្ធបរិស័ទចំណុះជើងវត្តនីមួយៗ តែងតែស្តាប់ឱវាទព្រះសង្ឃចៅអធិការ អំពីកិច្ចការព្រះពុទ្ធសាសនា ក៏ដូចជាជីវភាពប្រចាំថ្ងៃ ដូចជាការរំលឹកដាស់តឿនឲ្យខំប្រឹងប្រែងប្រកបការងាររដោយសុចរិត ដោយមិនដេកចាំសំណាង កុំទាស់ទែងខ្វែងគំនិតគ្នារវាងប្តីប្រពន្ធ និងអ្នកជិតខាងជាដើម ។ ប្រជាពលរដ្ឋពុទ្ធបរិស័ទខ្មែរទុកព្រះសង្ឃជាគ្រូរបស់ខ្លួន ដែលខ្លួនគប្បីយកឱវាទនោះមកពិចារណា ។ កូនចៅប្រុសជំនាន់ខ្មែរខ្លះ ត្រូវបានម្តាយឪពុកយកទៅទុកក្នុងវត្ត ដើម្បីសុំព្រះសង្ឃជួយអប់រំខាងសីលធម៌ ហើយឲ្យបួសជាសាមណេរជាភិក្ខុ បើសឹកមកវិញគេហៅថា ***អន្ទិត*** ដែ-លក្លាយមកពីពាក្យ ***បណ្ឌិត*** ដែលប្រែថាអ្នកចេះដឹង ។ កូនចៅខ្មែរអ្នកស្រែចំការដែលក្រីក្រ បានសំណាក់នៅក្នុងវត្តជាពិសេសវត្តនៅទីក្រុង ដើម្បីបន្តការសិក្សានៅអនុវិទ្យាល័យ និងមហាវិទ្យាល័យរបស់រដ្ឋ ព្រោះរដ្ឋពុំបានរៀបចំឲ្យមានផ្ទះសំរាប់និស្សិតស្នាក់នៅឡើយ ។ ក្រៅពីនោះ ព្រះសង្ឃបានជួយកិច្ចការខាងសង្គមកិច្ចជាច្រើនទៀត ដូចជាធ្វើជាអ្នកដឹកនាំកសាងសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ជាដើម ។

ពុទ្ធសាសនិកជនខ្មែរចាត់ទុកវត្តអារាមនិងព្រះសង្ឃ ជាទីកន្លែងនិងជាបុគ្គលដែលខ្លួនគប្បីគោរពបូជា ។ ដូច្នេះហើយ បានជាពេលចូលវត្ត បើមានពាក់មួកតែងដោះមួក ពេលចូលព្រះវិហារ និងទីកន្លែងមានព្រះពុទ្ធរូប បើពាក់ទ្រនាប់ជើងតែងតែដោះចេញ ហើយថ្វាយបង្គំដោយសេចក្តីគោរព ។ កាលជំនាន់ដើម បើមានមនុស្សមានការភិតភ័យអំពីបញ្ហាអ្វីមួយរត់ចូលវត្ត ប៉ូលិសមិនហ៊ានចូលលុកលុយចាប់មនុស្សក្នុងវត្តឡើយដោយការគោរពទីវត្ត និងគោរពព្រះសង្ឃ ព្រោះអ្នករត់ចូលវត្ត គឺរត់រកទីពឹងពីការគំរាមកំហែងបែបណាមួយពីជនឬក្រុមណាមួយ ។ ប្រៀបដូចមនុស្សរត់ទៅក្រៅប្រទេស ឬរត់ចូលស្ថានទូតណាមួយ ដើម្បីគេចពីការគំរាមកំហែងដល់ជីវិតពីរដ្ឋាភិបាលផ្តាច់ការ ដែលអង្គការសហប្រជាជាតិមានច្បាប់សំរាប់ការពារជនមានលក្ខណៈបែបនេះ ។ សម័យពុទ្ធកាល ក្នុងបិដកខ្មែរភាគ៦ក៏មាននិយាយថា ព្រះបាទពិម្ពិសារបានអនុញ្ញាតដល់ជនដែលមានទោស ហើយរត់មកបួសមិនឲ្យបុគ្គលណាមួយធ្វើទោសដល់ជននោះឡើយ ដោយព្រះរាជឱង្ការថា ជនទាំងឡាយណាដែលបួសក្នុងសំណាក់ ***សមណសក្យបុត្រ*** ជនដទៃធ្វើទោសអ្វីដល់ជនពួកនោះមិនបានឡើយ

ព្រោះថាព្រះធម៌ព្រះដ៏មានព្រះភាគទ្រង់សំដែងល្អហើយ ជនពួកនោះចូរខំប្រព្រឹត្តព្រហ្មចរិយា ដើម្បីធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខដោយប្រពៃចុះ ។ ត្រង់ចំណុចនេះ គួរពិចារណាព្រះវិន័យត្រង់ **បព្វជ្ជាខន្ធ** ថា ព្រះពុទ្ធមិនអនុញ្ញាតឲ្យបុគ្គលដែលជំពាក់បំណុលគេ បុគ្គលមានទោសបួសឡើយ ព្រោះដើម្បីកុំឲ្យមានរឿងរ៉ាវក្នុងសហគមន៍ព្រះសង្ឃ ។

ពោលដោយសង្ខេប **វត្ត** និង **ព្រះសង្ឃ** ជាមូលដ្ឋាននៃវប្បធម៌ខ្មែរ ឬជាព្រលឹងអត្តសញ្ញាណខ្មែរ ស្ថិតនៅក្នុងចិត្តគំនិតខ្មែរជានិច្ច ដែលពុំអាចបំបែកបាន ។ ភស្តុតាងខ្មែរក្រហមបានបំផ្លាញព្រះពុទ្ធសាសនាដល់ឫសគល់ តែវាបរាជ័យវិនាសខ្លួនឯង ចំណែកព្រះពុទ្ធសាសនាស្ថិតនៅក្នុងចិត្តគំនិតខ្មែរដដែល ។៚